ថ្ងៃ៨ល្អ ខែ12 ឆ្នាំ2021
សមាគមGTS

# ជូនទៅកាន់កម្មសិក្សាការីទាំងអស់គ្នា

ចូលដល់ខែធ្នូ（ខែ12）អាកាសធាតុកាន់តែត្រជាក់។
កម្មសិក្សាការីទាំងអស់គ្នា តើអ្នកសុខសប្បាយជាទេ?

ថ្មីៗនេះ ចំនួនអ្នកឆ្លងវីរុសកូរ៉ូណាថ្មី បានថយចុះ ប៉ុន្តែប្រភេទ អូមីក្រុងថ្មី ក៏ត្រូវបានរកឃើញនៅក្នុងប្រទេសជប៉ុនផងដែរ។ សូមប្រុងប្រយ័ត្នចំពោះសុខភាព និង មានវិធានការបង្ការអស់លទ្ធភាព ដើម្បីស្វាគមន៍ឆ្នាំថ្មីប្រកបដោយសុខមាលភាពល្អ។ លើសពីនេះទៅទៀតក្នុងអំឡុងពេលថ្ងៃឈប់សម្រាកយូរ មានការប្រើប្រាស់អគ្គិសនីយខ្វះខ្នាយ។ សូមព្យាយាមសន្សំសំចៃអគ្គិសនី ហើយប្រយ័ត្នពេលចេញទៅក្រៅដោយបើកម៉ាសីុនកំដៅចោល។

សូមចងចាំ ខាងក្រោមនេះជាចំនុចប្រុងប្រយ័ត្នសម្រាបការឈប់សម្រាកថ្ងៃបុណ្យឆ្លងឆ្នាំ និង ចូលឆ្នាំសកល។

## ចំណាំ

### 1.អំពីការការពារការឆ្លងមេរោគកូរ៉ូណាថ្មី

・ពាក់ម៉ាស, ជៀសវាងការនិយាយជាមួយមនុស្សដោយមិនបានពាក់ម៉ាស
・រក្សាគម្លាតរវាងគ្នានឹងគ្នាចាប់ពី១ម៉ែតឡើងទៅ
・ជៀសវាងការជួបជុំទ្រង់ទ្រាយធំនិងពិធីជប់លៀងផឹកស៊ីរយះពេលយូរ
・ខ្យល់ឱ្យបានទៀងទាត់

https://www.otit.go.jp/CoV2_jissyu_kansen/　←សូមពិនិត្យនៅទីនេះ　សំរាប់ការបញ្ជាក់បន្ថែម

### 2.អំពីជំងឺ

ការការពារជំងឺផ្ដាសាយ ផ្ដាសាយធំប្រភេទថ្មី
・ពេលត្រលប់មកពីខាងក្រៅ, មុនចំអិនអាហារដាច់ខាតត្រូវលាងដៃនិងខ្ពុរមាត់។
・ត្រូវរស់នៅដោយត្រឹមត្រូវទៅតាមច្បាប់ ◌ះ(កុំនៅដល់យប់ជ្រៅពេក)
・ត្រូវយកចិត្តទុកដាក់ទៅលើរបបអាហារញុំាដែលផ្តល់ជីវជាតិគ្រប់គ្រាន់។

### 3. អំពីគ្រោះថ្នាក់ចរាចរណ៍

ត្រូវគោរពច្បាប់ចរាចរណ៍ប្រទេសជប៉ុនអោយបានខ្ជាប់ខ្ជួន ដើម្បីកុំអោយជួបគ្រោះថ្នាក់ចរាចរ

សិនបើមានគ្រោះថ្នាក់កើតឡើង
ទូរស័ព្ទដៃជាមួយនិងកាតស្នាក់នៅ និងកាតទំនាក់ទំនង, នៅពេលកើតស្ថានភាពមិនបានគ្រោងទុក ត្រូវរក្សាអារម្មណ៍ ហើយសូមទំនាក់ទំនងទៅអ្នកស្នាក់នៅជាមួយ និងសមាគម
លើសពីនេះ, ត្រូវគោរពច្បាប់ចរាចរពេលជិះកង់។ គោរពច្បាប់ចរាចរ គឺគោរពជីវិតខ្លួនឯង

## 4. អំពីការងារក្រៅម៉ោង

ការងារក្រៅម៉ោងនិងការងារធ្វើតាមផ្ទះ ត្រូវបានហាមឃាត់មិនឲ្យកម្មសិក្សាការីធ្វើនោះទេ!
ថ្វីបើទទួលបានសិទ្ធស្នាក់នៅក៏ដោយ មានន័យថាអ្នកជាកម្មសិក្សាការីកហាត់ជំនាញគឺ "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 1R" និង "ការហ្វឹកហ្វឺនបច្ចេកទេសលេខ 2 R"។
ការទទួលយកប្រាក់ឈ្នួលនៅតាមគ្រឹះស្ថាននិងហាងផ្សេងៗគឺជាសកម្មភាពខុសច្បាប់
ហើយនឹងបណ្ដាលឲ្យក្រុមហ៊ុននិងសមាគមរបស់អ្នកត្រូវទទួលទោសផងដែល!
លើសពីនេះទៅទៀតវាជាសកម្មភាពមួយខុសពីការហ្វឹកហ្វឺនជំនាញជាក់ស្ដែង
ហើយអ្នកនឹងត្រូវបញ្ជូនវិលត្រឡប់ទៅផ្ទះវិញ។

## 5. អំពីការរញ្ជួយដី

ប្រទេសជប៉ុនត្រូវបានគេដឹងថាជាប្រទេសដែលមានការរញ្ជួយដីជាច្រើន។
ប្រសិនបើមានការរញ្ជួយដីកើតមានឡើងតើអ្នកគួរធ្វើអ្វី? តើអ្នកទាំងអស់គ្នាដឹងដែរឬទេ? បន្ទាប់ពីអ្នកមើលសៀវភៅ ( http://www.fdma.go.jp/relocation/bousai_manual/index.html ) ស្ដីពីសៀវភៅណែនាំអំពីការការពារគ្រោះមហន្តរាយរបស់ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយនិងទីភ្នាក់ងារអគ្គីភ័យ អ្នកនឹងទទួលបានទទួលចំណេះដ៏ល្អ។

## 6.ផ្សេងៗ

ដាច់ខាតត្រូវគោរពច្បាប់ក្រុមហ៊ុន ច្បាប់នៅកន្លែងស្នាក់នៅ និងច្បាប់របស់ប្រទេសជប៉ុន។
ឧក្រិដ្ឋជនត្រូវបានដាក់ទោសដោយមិនគិតពីជនជាតិជប៉ុនឬជនបរទេសឡើយ។
ប្រសិនបើអ្នកធ្លាប់ជាប់បទព្រហ្មទណ្ឌហើយ អ្នកនឹងមិនអាចលុបប្រវត្តិនោះបានទេ។

- ហាមឃាត់ការស្នាក់ខាងក្រៅដោយមិនមានការអនុញ្ញាត។ ចូរសុំច្បាប់ពីក្រុមហ៊ុនឬសមាគមជាមុនសិន។
- គ្រូបង្រៀនណែនាំការរស់នៅអាចនឹងដើរត្រួតពិនិត្យកន្លែងស្នាក់នៅគ្រប់ពេល ! ប្រសិនបើមានបញ្ហា អ្នកត្រូវតែទាក់ទងទៅសមាគមផង។វានឹងមានការលំបាកស្នើសុំបច្ចុប្បន្នភាព VISA ទៅកាន់អន្តោប្រវេសន៍ ប្រសិនបើអ្នកត្រូវបានគេបញ្ជាក់ថាអាកប្បកិរិយាក្នុងការរស់នៅរបស់អ្នកមិនល្អ។
  នេះជាច្បាប់ដើម្បីឲ្យអ្នកទាំងអស់គ្នានៅប្រទេសជប៉ុនដោយសុវត្ថិភាពតែប៉ុណ្ណោះ !
  ដូចនេះហើយអ្នកត្រូវគោរពវិន័យ ហើយកុំសប្បាយមួយពេលដែលធ្វើឲ្យអ្នកខូចអនាគត !

### ការលួចទំនិញតាមហាង

### និងជិះកង់ដែលគេទុកចោលទាំងនេះគឺជាអំពើខុសច្បាប់

### ដែលមិនអាចលើកលែងបាន!

ជាអកុសលមានការកើនឡើងចំនួនករណីឧក្រិដ្ឋកម្មដែលបង្ករដោយក្នុងពេលរីកហាត់ជំនាញ !
មិនត្រូវជឿពាក់លួងលោមសូម្បីតែជាជនជាតិដូចគ្នា។ពាក្យផ្អែមល្ហែមគឺជាអន្ទាក់។សូមជឿជាក់លើខ្លួនឯង !

មិនត្រូវឲ្យលិខិតឆ្លងដែននិងប័ណ្ណស្នាក់ទៅកាន់នរណាម្នាក់ក្រៅពីសមាគម ឬក្រុមហ៊ុនទេ !
អ្នកនឹងមិនតម្រូវឲ្យស្ទើរដោយផ្ទាល់ខ្លួននៅខាងអន្តោប្រវេសន៍ទេ។ជនខិលខូចនតែងតែចង់បានលិខិតឆ្លងដែន ឬប័ណ្ណស្នាក់នៅរបស់អ្នក!
សូមប្រុងប្រយ័ត្ន!

ចប់